**ការជួយ (aiding)**

ការជួយ គឺជាទម្រង់សមគំនិត (complicity) ដែលសំដៅដល់ការជួយ ឬការលើកទឹកចិត្តដល់ការប្រព្រឹត្តបទល្មើស។ ការជួយ ត្រូវតែមានផលវិបាកធន់ល្មម (substantial effect) និង ចូលរួមបន្ថែមលើសកម្មភាពល្មើសរបស់ចារី (principal)។ ក្នុងន័យនេះ អ្នកជួយ ដោយចៃដន្យ នឹងមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ការណ៍គ្រាន់តែមានវត្តមាននៅទីកន្លែងកើតហេតុ មិនមែនជាការជួយទេ ប្រសិនបើជននោះមិនបានចូលរួម និង មិនបានដឹងថា វត្តមានរបស់ខ្លួន បានជួយដល់ការប្រព្រឹត្តបទល្មើស។

សម្រាប់ទំនាក់ទំនងរវាងអ្នកជួយនិងចារី ប្រសិនបើអំពើរបស់ចារី មានយុត្តិកម្ម (justification) រួចផុតពីការទទួលខុសត្រូវ អ្នកជួយក៏នឹងរួចផុតពីការទទួលខុសត្រូវផងដែរ។ ផ្ទុយទៅវិញ អ្នកជួយ នឹងនៅតែទទួលខុសត្រូវ ទោះបីជាចារី ត្រូវបានសម្រេចមិនឲ្យទទួលខុសត្រូវផ្អែកលើមូលដ្ឋាននៃការដោះសារ (excuse) ក្តី។

សំណួរអាចត្រូវបានចោទសួរថា តើគេអាចជួយ បទល្មើសប៉ុនប៉ង (inchoate crimes) ដែរឬទេ? ។ សម្រាប់យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ នៅមានភាពមិនទាន់ច្បាស់លាស់ ថាតើមានការទាមទារ ឲ្យអ្នកជួយ មានគោលបំណង ឬ បានដឹង (knowledge) ដែលជាផ្នែកមួយនៃធាតុផ្សំអត្តនោម័ត (*mens rea*) ដែរឬទេ? លក្ខន្តិកៈនៃ ICC ទាមទារនូវគោលបំណងនៃការជួយ។

យុត្តិសាស្ត្រ *Tadic*, IT-94-1-A, 1999, S. 229 បានសង្ខេបរួមនូវធាតុផ្សំនៃការជួយ៖ ១. អ្នកជួយ ជាជនសមគំនិតដល់បទឧក្រិដ្ឋរបស់ចារី។ ២. មិនមានការទាមទារគោលបំណង ឬកិច្ចព្រមព្រៀងរវាងអ្នកជួយ និង ចារី ហើយចារីមិនចាំបាច់ដឹងអំពីការជួយរបស់អ្នកជួយទេ។ ៣. អ្នកជួយ ប្រព្រឹត្តសកម្មភាពជាក់លាក់ ក្នុងគោលបំណងជួយ និងទី ៤. អ្នកជួយដឹងថា ទង្វើរបស់ខ្លួន ជួយដល់ការប្រព្រឹត្តបទល្មើស។

ទោះបីជានៅក្រោមច្បាប់ជាតិមួយចំនួន អ្នកជួយ ត្រូវបានដាក់ទោសស្រាលជាងចារីក្តី តុលាការព្រហ្មទណ្ឌអន្តរជាតិ ផ្តល់ទោសដូចគ្នា គឺទោសក្នុងពន្ធនាគារមួយជីវិត (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 239-240)។